00665555

E9/27

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីរបស់អ្នកស្រី អៀង ធីរិទ្ធ

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 19 / 04 / 2011
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ: **សាធារណៈ / Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើរបស់អ្នកស្រី អៀង ធីរិទ្ធ សុំដាក់បញ្ចូលឯកសាររបស់ខ្លួន

---

**<u>សហមេធាវីការពារក្តីរបស់អ្នកស្រី អៀង ធីរិទ្ធ៖</u>**

លោក ផាត់ ពៅស៊ាង

កញ្ញា Diana ELLIS, QC

**<u>ចៅក្រមអង្គជំនុំជម្រះសាលាដំបូង៖</u>**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម ធូ មណី

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖</u>**

លោក ពេជ អង្គ

លោកស្រី Elisabeth SIMONNEAU FORT

**<u>សហព្រះរាជអាជ្ញា៖</u>**

លោកស្រី ជា លាង

លោក Andrew CAYLEY

១. នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចទទួលយកសំណុំរឿង ០០២ និងបានបញ្ជាក់នៅក្នុង "ដីកាបង្គាប់ឱ្យដាក់សម្ភារៈដើម្បីរៀបចំសវនាការ "**ដីកាបង្គាប់**"[១] ថា ភាគីទាំងអស់ត្រូវដាក់បញ្ជីឯកសារ និងវត្ថុតាង "**បញ្ជីឯកសារ**" ឱ្យស្របតាមដីកាបង្គាប់ខាងលើ ដោយមិនឱ្យហួសពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១១ ឡើយ[២]។ នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សាណៈមួយផ្ញើជូនភាគីទាំងអស់ ដោយជម្រាបជូនពួកគេអំពីការឈប់សម្រាករបស់អង្គជំនុំជម្រះសាលាដំបូង ចាប់ពីថ្ងៃទី ១១ ដល់ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១១[៣]។ ឯកសារដែលអាចដាក់ជូននៅក្នុងពេលឈប់សម្រាកនេះនឹងពុំទទួលយកបានឡើយ។ ជាលទ្ធផល បញ្ជីឯកសារទាំងអស់ត្រូវដាក់នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១។

២. មេធាវីការពារក្ដីរបស់អ្នកស្រី អៀង ធីរិទ្ធ (**ជនជាប់ចោទ**) សូមដាក់បញ្ជីឯកសាររបស់ខ្លួនដែលភ្ជាប់ជាមួយសំណើរសុំនេះជា **ឧបសម្ព័ន្ធ ១** និងតារាងភស្តុតាងដែលភ្ជាប់មកជាមួយជា **ឧបសម្ព័ន្ធ ២**។

៣. មេធាវីការពារក្ដីសូមជម្រាបជាថ្មីម្ដងទៀតថា ក្នុងពេលថ្មីៗនេះ មេធាវីការពារក្ដីមិនបានទទួលការណែនាំពីជនជាប់ចោទទេ។ ហេតុដូច្នេះ ការជ្រើសរើសឯកសារនេះ ត្រូវបានធ្វើឡើងដោយមេធាវីការពារក្ដី ក្នុងនាមឱ្យជនជាប់ចោទ។ មេធាវីការពារក្ដីសូមសំណូមពរដោយគោរពដើម្បីឱ្យមានការធានាថា មេធាវីការពារក្ដីសូមរក្សាសិទ្ធិរបស់ខ្លួនដើម្បីដាក់ឯកសារបន្ថែមទៀត ទៅក្នុងបញ្ជីឯកសារនេះ ក្នុងករណីដែលកាលៈទេសៈមានការប្រែប្រួល ហើយជនជាប់ចោទអាចណែនាំដល់មេធាវីការពារក្ដីរបស់ខ្លួននាពេលខាងមុខ និងអាចចូលរួមយ៉ាងសកម្មនៅក្នុងការរៀបចំការការពារខ្លួនឱ្យបានត្រឹមត្រូវ។

៤. លោកស្រី Susan Lamb ដែលជាមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងបានផ្ញើអ៊ីមែលមួយច្បាប់ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១១ ជូនភាគីទាំងអស់ ដោយបានបញ្ជាក់ថា៖

> អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់ថា នៅថ្ងៃទី ១៩ ខែ មេសា ភាគីទាំងអស់មានកាតព្វកិច្ចដាក់តែឯកសារទាំងឡាយណា ដែលជាប់ទាក់ទិននឹងសាក្សីរបស់ខ្លួន ដែល

---

[១] អ.ជ.ស.ដ ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ E9។

[២] ដីកាបង្គាប់ កថាខណ្ឌ ១២ ។

[៣] អ.ជ.ស.ដ អនុស្សារណៈ ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ ២០១១ ឯកសារលេខ E68។

បានស្នើសុំ និងករណីប្រឆាំងនឹងកូនក្ដីជាក់លាក់របស់ខ្លួនតែប៉ុណ្ណោះ។ ភាគីមិន មានកាតព្វកិច្ចដាក់ឯកសារដែលបានសន្មតថា មានការពាក់ព័ន្ធនឹងសាក្សីដែលត្រូវបានស្នើសុំឱ្យកោះហៅដោយភាគីដទៃទៀតនោះទេ។

៥. អាស្រ័យហេតុនេះ មេធាវីការពារក្ដីនឹងដាក់ជូនតែឯកសារទាំងឡាយ ដែលខ្លួនយល់ថាជាប់ពាក់ព័ន្ធនឹងរឿងក្ដី និងសាក្សីរបស់ខ្លួនតែប៉ុណ្ណោះ ហើយមេធាវីការពារក្ដីគិតថា ភាគីដទៃទៀតក៏នឹងដាក់តែឯកសារណា ដែលជាប់ពាក់ព័ន្ធនឹងកូនក្ដីរបស់ខ្លួនផ្ទាល់តែម្ដង។ ប្រសិនបើភាគីណាមួយខកខានមិនបានធ្វើដូច្នេះទេ នោះមេធាវីការពារក្ដីសូមរក្សាសិទ្ធិដើម្បីធ្វើការឆ្លើយតបទៅនឹងឯកសារដែលភាគីដទៃទៀតខកខានមិនបានដាក់ជូននៅក្នុងបញ្ជីឯកសាររបស់ខ្លួន ហើយដែលឯកសារនោះជាប់ពាក់ព័ន្ធនឹងសាក្សីជាក់លាក់ណាម្នាក់។

៦. វិធាន ៨៤ នៃវិធានផ្ទៃក្នុងអនុញ្ញាតឱ្យជនជាប់ចោទ "មានសិទ្ធិដាច់ខាតស្នើសុំឱ្យកោះហៅសាក្សីដាក់បន្ទុក ដែលជនជាប់ចោទមិនទាន់មានឱកាសតទល់នៅដំណាក់កាលមុនពេលជំនុំជម្រះក្ដី"។ ប្រសិនបើសហព្រះរាជអាជ្ញាមានបំណងចង់ដាក់កំណត់ហេតុស្ដាប់ចម្លើយសាក្សី ដែលបានធ្វើនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត មកធ្វើជាភស្តុតាងដាក់បន្ទុកមកលើជនជាប់ចោទ នោះមេធាវីការពារក្ដីសូមជំទាស់ថា សាក្សីទាំងនោះគួរតែមកផ្ដល់សក្ខីកម្មដោយផ្ទាល់ ដោយហេតុថា មេធាវីការពារក្ដីមានសិទ្ធិដាច់ខាតក្នុងការសួរតទល់នឹងសាក្សីបែបនេះបាន។ មេធាវីការពារក្ដី សូមសង្កត់ធ្ងន់ថា សិទ្ធិនេះអនុវត្តតែក្នុងទម្រង់ដាច់ខាតចំពោះជនជាប់ចោទតែប៉ុណ្ណោះ គឺមិនអនុវត្តចំពោះភាគីដទៃទៀតនោះទេ។

៧. ជាចុងក្រោយ បញ្ហានៃការឆ្លើយថាភាពទៅលើឯកសារ ត្រូវបានលើកឡើងនៅក្នុងកិច្ចប្រជុំរៀបចំសវនាការ[៤]។ តាមរយៈនេះ មេធាវីការពារក្ដីសូមជម្រាបជូនអង្គជំនុំជម្រះសាលាដំបូងថា មេធាវីការពារក្ដីមិនបានឆ្លើយថាភាពទៅលើឯកសារស្ដីពីបញ្ជីឯកសាររបស់ខ្លួនទេ ហើយមេធាវីការពារក្ដីក៏មិនមានតួនាទីអាចធ្វើបែបនេះបានដែរ។ មេធាវីការពារក្ដីសូមរក្សាសិទ្ធិដើម្បីជំទាស់តវ៉ាទៅលើការឆ្លើយថាភាពឯកសារទាំងអស់ដែលបានយកមកធ្វើជាភស្តុតាង នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ វាជាកត្តាសំខាន់ចំពោះសវនាការប្រកបដោយយុត្តិធម៌ដែលថា ប្រភពដើមនៃឯកសារនីមួយៗ ដែលត្រូវបានយកមកធ្វើជាសំអាងដោយអង្គជំនុំជម្រះសាលាដំបូងនោះ គួរតែត្រូវ

[៤] សូមមើល សេចក្ដីព្រាងប្រតិចារិកនៃកិច្ចប្រជុំរៀបចំសវនាការ ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ ទំព័រ ៧៤។

បានកំណត់អត្តសញ្ញាណឲ្យបានត្រឹមត្រូវ ទើបអាចបញ្ជាក់ពីយថាភាពរបស់ឯកសារនេះបាន ទោះបីជាភាពអាចទទួលយកបានអាចមិនមែនជាបញ្ហាដូចគ្នាទៅនឹងទម្ងន់នៃភស្តុតាងដែលភ្ជាប់ទៅនឹងឯកសារនេះ ក៏ដោយ។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះមេធាវីការពារក្តី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីរបស់ អ្នកស្រី អៀង ធីរិទ្ធ | ថ្ងៃទី ១៨ ខែមេសា ឆ្នាំ ២០១១ | លោក ផាត់ ពៅស៊ាង<br>Diana ELLIS, QC | ភ្នំពេញ | P.P. [signature] |